# *រឿងធនញ្ជ័យ*

### *ភាគទី៩*

*...អាចារ្យចិនក៏ព្រមឲ្យរបស់ក្នុងសំពៅទាំង៤នោះ ហើយក៏បើកសំពៅទៅស្រុកវិញ ឯធនញ្ជ័យកាលបើបានរបស់អំពីសំពៅទាំង៤នោះហើយ ឲ្យជញ្ជូនអស់របស់ទ្រព្យនោះទៅថ្វាយព្រះបាទជាម្ចាស់ទាំងអស់ នឹងមានយកជារបស់ខ្លួនក៏ទេ ឯព្រះមហាក្សត្រ បានលឺថាធនញ្ជ័យឈ្នះប្រស្នាអាចារ្យចិនដូច្នោះហើយ លុះដល់ឃើញធនញ្ជ័យឲ្យជញ្ជូនអស់របស់ទ្រព្យមកថ្វាយដូច្នោះក៏ត្រេកអរក្នុងព្រះរាជហឫទ័យ ហើយមានព្រះបន្ទូលថា ធនញ្ជ័យឯងបានទុកខ្លះហើយរឺទេរបស់ទាំងអស់នេះ ធនញ្ជ័យក្រាបទូលថា ទូលព្រះបង្គំពុំបានយកទុកទេស្ដេចស្ដាប់ហើយក៏មានបន្ទូលថា បើដូច្នោះអញនឹងឲ្យយកស្រីក្នុងវាំងធ្វើជាប្រពន្ធឯង ហើយនឹងរបស់ទ្រព្យទាំងអស់គ្រប់មុខកុំឲ្យមានខ្វះខាតរបស់អ្វី ឯធនញ្ជ័យក្រាបទូលថា ទូលបង្គំមិនចង់បានទេ ប្រពន្ធនោះត្បិតមិនមែនជាស្រីទេ ឈ្មោះញី មិនប្រាកដជាស្រី សូមជ្រាប ស្ដេចទ្រង់សណ្ដាប់ហើយក៏មានព្រះបន្ទូលថា ឯណាឈ្មោះស្រីនោះទើបធនញ្ជ័យថា ទូលព្រះបង្គំនឹងក្រាបថ្វាយបង្គំលាទៅរក បើបាននឹងនាំមកថ្វាយ ហើយទូលថា សូមព្រះអង្គព្រះរាជទានសំពត់ហូល ព្រែ ឲ្យច្រើននឹងទៅរកស្រីនោះទើបឃើញ ស្ដេចស្ដាប់ហើយ ព្រះរាជទានហូលព្រែឲ្យធនញ្ជ័យជាច្រើន ហើយទ្រង់ផ្ដាំថា បើរកបានវិលមកឆាប់ ឯធនញ្ជ័យក្រាបទូលថ្វាយបង្គំលា យករបស់នោះវេចស្រេចហើយ ស្ពាយសំពាយដើរទៅស្រីនោះៗ*

*លុះដល់ទីណាមានគេនៅច្រើននោះ ចូលទៅសួរគេថា ស្រុកនេះមានស្រីរឺទេ អ្នកស្រុកប្រាប់ថាស្រីមានដែរ ទើបធនញ្ជ័យថា មិនមែនស្រីទេ នេះជាហៅថាឈ្មោះញី មិនមែនស្រីទេ ធនញ្ជ័យថាហើយដើរទៅរកភូមិគេឯទៀត ហើយចូលទៅសួរថា ក្នុងស្រុកនេះ តើមានស្រីរឺទេ អស់អ្នកស្រុកប្រាប់ថា ខ្ញុំធ្លល់ណាស់ ចុះអស់ទាំងអស់ស្រីនេះ តើគេហៅថាជាអ្វីវិញ ឯធនញ្ជ័យថា ទេនេះគេហៅញីទេ ថាហើយក៏ដើរទៅរកស្រីឯទៀត លុះទៅដល់ភូមិផ្ទះនាងសួស្ដី ហើយដើរទៅសួររកស្រី ក៏ប្រទះនឹងនាងសួស្ដីមកអង្គុយនៅដីមុខផ្ទះនោះឯង ឯធនញ្ជ័យចុលទៅដល់ហើយក៏ដណ្ដឹងសួរថា អ្នកប្អូននៅទីនេះមានស្រីទេ ឯនាងសួស្ដីស្ដាប់ហើយឆ្លើយថា អ្នកឯងនេះនៅស្រុកណា មានទេប្រុសក្នុងស្រុកអ្នកឯង ឯធនញ្ជ័យស្ដាប់*

*អត្ថបទដោយៈ មាស សុភាព*

ហើយក៏គិតថា ហើយគេហៅថាស្រីសួស្តី ទើបធនញ្ជ័យប្រាប់ថា ឯស្រុកខ្ញុំមានប្រុសដែរ តើនាងដឹងឬទេ ឈ្មោះប្រុសនោះឯង នាងសួស្តីថា ខ្ញុំដឹងបានជាគេហៅប្រុសនោះ ត្បិតគេឈ្មោះជ័យនោះឯង ជ័យនោះច្រើនជាធំជាងអស់ឈ្មោះផង ជ័យឈ្នះអស់ក្នុងផែនដីនេះ ឯងបានជាហៅប្រុសៗ ត្បិតឈ្មោះជ័យនោះឯង ទើបនាងសួស្តីថា អ្នកឯងស្គាល់ទេស្រីនោះ ទើបធនញ្ជ័យថា ខ្ញុំស្គាល់បានជាគេហៅស្រីៗនោះត្បិតតែឈ្មោះ សួស្តីនោះឯង ជាសួស្តីមង្គលជាធំក្នុងផែនដីនេះ នឹងយកឈ្មោះណាឲ្យដូចគ្មាន បានជាគេហៅស្រីៗនោះ ត្បិតតែឈ្មោះសួស្តី ទើបធនញ្ជ័យសួរថា នាងមានខ្លាច ឬគ្មានខ្លាចទេ នាងសួស្តីឆ្លើយថា ខ្ញុំគ្មានខ្លាចទេ ថាអ្នកឯងតើមានក្រែង ឬមិនក្រែងទេ ធនញ្ជ័យឆ្លើយថា ខ្ញុំគ្មានក្រែងអ្វីទេ ហើយធនញ្ជ័យដណ្តឹងថា ខ្ញុំសួរនាងថា ខ្លាចគ្មានខ្លាចនោះ តើនាងដឹងរឺទេ នាងសួស្តីឆ្លើយថា ខ្ញុំដឹងហើយ គឺអ្នកបណ្តឹងថា មានប្តីរឺនៅឡើយ បើមានប្តីហើយខ្លាចប្តីដេរបើគ្មានប្តីទេ នោះថាមិនខ្លាចទេ ទើបនាងសួស្តីដណ្តឹងថា ក្រែងរឺមិនក្រែង នោះតើអ្នកថាដូចម្តេច ទើបធនញ្ជ័យប្រាប់ថា ខ្ញុំដឹងនាងឯងសួរខ្ញុំថា មានប្រពន្ធហើយរឺនៅទេ បើមានប្រពន្ធហើយក្រែងចិត្តប្រពន្ធនោះ បើគ្មានប្រពន្ធទេថាមិនក្រែងចិត្តនរណាទេ ឯធនញ្ជ័យបានដឹងថានាងសួស្តីគ្មានប្តីដូច្នេះហើយ ក៏ដាក់សំពាយអំពីស្មា ហើយស្រាយសំពាយហូលចេញឲ្យម្តាយឪពុកនាងសួស្តីឃើញ។

ឯម្តាយឪពុកនាងសួស្តីឃើញហូលព្រៃធនញ្ជ័យ ក៏ដើរមកមើលហើយសួរថា អ្នកកូននឹងយកទៅណា ឯធនញ្ជ័យសំពះជំរាបសួរថា ខ្ញុំយកមករកប្រពន្ធទេ បើលោកម្តាយលោកឪពុកមេត្តាខ្ញុំ ខ្ញុំនឹងបំរើជាកូនក្នុងផ្ទះដងទឹក កាប់អុស បុកស្រូវ ខ្ញុំចេះតែព្រម មិនខ្ជិលប្រអូសឡើយ ឯម្តាយឪពុកនាងសួស្តី និងខ្លួននាងសួស្តីក៏ឡើងលើផ្ទះ ហើយប្តី និងប្រពន្ធនិយាយគ្នាថា ចៅកំលោះនេះចង់បានកូនយើងហើយ គិតតែពីរនាក់ថា បើដោយស្មានមើលទៅឃើញជាកូនគេអ្នកមានណាស់ មានទាំងហូលព្រៃនោះច្រើន យើងល្មមឲ្យកូនយើងហើយ ឯធនញ្ជ័យកាលបើម្តាយឪពុកក្មេកឡើងលើផ្ទះហើយ ក៏វេចបង្វិចដើរទៅទីណាកំបាំង ហើយយកក្រដាសមកសរសេរកត់ជាចំណាំឈ្មោះនាម៉ឺនតូចធំដែលជំពាក់ប្រាក់ ខ្លះជំពាក់១០០តម្លឹង ខ្លះជំពាក់២០០តម្លឹង ខ្លះជំពាក់៥០០តម្លឹង បានច្រើនហើយចង១បាច់ ដាក់ក្នុងសំពាយឡើងទៅលើផ្ទះសំពះម្តាយឪពុកក្មេក ហើយអង្គុយនៅស្ងៀមចាំស្តាប់។ ម្តាយឪពុកនាងសួស្តីក៏ដណ្តឹងថា អញនឹងចង់សួរចិត្តជីឯងៗចង់បានកូនអញមែនរឺទេ ទើបធនញ្ជ័យសំពះហើយជំ

អត្ថបទដោយៈ មាស សុភាព

រាបថា ក្នុងចិត្តខ្ញុំបាទចង់បាន ក្រែងតែលោកមិនឲ្យទានខ្ញុំបាទ បើលោកមេត្តាជាកូនជាចៅនោះក៏អរគុណណាស់ នឹងនៅបំរើអស់ចិត្ត ឯម្ដាយឪពុកនាងសួស្ដី ថាយើងឲ្យហើយ ចូរឯងទៅរកទិញមាន់ ទា ជ្រូក អណ្ដើក កុំខាន បើមិនបានអណ្ដើកនោះ មេបាយើងមិនទទួលទេ។

ឯធនញ្ជ័យបានលឺពាក្យម្ដាយឪពុកក្មេកបង្គាប់ដូច្នោះហើយ ក៏ដើរទៅរកអស់អ្នកស្រុកភូមិទាំងនោះ រើសរកតែអ្នកដែលមានប្ដីប្រពន្ធអំពីកំលោះក្រមុំ ទើបយក ហើយឲ្យឈ្មោះថាមេអណ្ដើកទើបរកស្រី៤នាក់ទៀត បើបានច្រើនដល់៨ ឬ១៤នាក់ នោះរឹងរឹតតែជាការល្អ ឲ្យតែមានប្ដីអំពីក្មេង បើទើបមានកូន១ ក៏បានដែរ ឲ្យឈ្មោះថាកូនអណ្ដើក ទើបរកមនុស្សប្រុសម្នាក់ដែលមានយសសក្ដិ មានប្រាជ្ញាឲ្យឈ្មោះជាអ្នកមហាអស់អ្នកប្រុសស្រីទាំងនោះ យកមកដណ្ដឹងកូនគេហើយ ធនញ្ជ័យឲ្យទិញអស់ទំនិញតាមបង្គាប់ម្ដាយឪពុកនាងសួស្ដី លុះទិញបានសព្វគ្រប់ហើយឲ្យអ្នកមហានាំទៅជូនម្ដាយឪពុកខាងស្រីខ្លះ ទុកខ្លះរៀបស្ងដណ្ដាំធ្វើនំគ្រប់មុខឲ្យហៅភ្ញៀវមកផឹកសង្កត់ពោងរួចហើយ ព្រឹកឡើងបានជ័យល្អហើយ អ្នកមហា និងមេអណ្ដើកក៏រៀបអស់បណ្ណាការនូវចិញ្ចៀន ត្រសាល់ទៅបំពាក់កូនស្រីនោះ ហើយឲ្យខាងស្រីនោះរៀបរោងចាំទទួលអស់អ្នកមហានូវបណ្ណាការនេះ។ ឯអ្នកមហា មេអណ្ដើក និងអស់ក្មេងដែលកាន់គ្រឿងបណ្ណាការនេះ។ ឯអ្នកមហា មេអណ្ដើក និងអស់ក្មេងដែលកាន់គ្រឿងបណ្ណាការដើរទៅដល់ហើយ អ្នកមេបាមកទទួលអ្នកមហាឡើងទៅលើរោង ទើបអ្នកមហាឲ្យយកស្រា២ដប តម្កល់នឹងជើងពានហើយ ទើបយកចង់មក យកក្មេងឲ្យកាន់រងថង់ហិប ហើយអ្នកមហាជំរាបថា យើងមកជំរាបអស់លោកមេបាចាស់ទុំសូមជ្រាបត្បិតយើងបានចិញ្ចៀន និងចារុត្រសាល មកសូមបំពាក់កូនស្រី ហើយសូមលើកស្វាដក់ស្វាកន្សែង ជំរាបរួចហើយទើបអស់អណ្ដើក ចូលទៅបំពាក់ចិញ្ចៀនកូនស្រីនោះរួចហើយ ទើបខាងស្រីនោះលើកថាសបាយ និងស្រាមកស៊ីផឹក រួចហើយលាគ្នាទៅផ្ទះទីទៃ។ ហៅថ្ងៃកំណត់ហោង។

លុះព្រឹកឡើងបានពេលា អ្នកមហា និងមេអណ្ដើក កូនអណ្ដើកនាំកូនប្រសារឈ្មោះធនញ្ជ័យ ទៅសំពះម្ដាយឪពុក ហើយយកកូនស្រីឈ្មោះនាងសួស្ដីមកផ្ទឹមនឹងធនញ្ជ័យ ហើយរាងបើកបាយខុនចងដៃរួចហើយ ដល់យប់ផ្សំដំនេក អ្នកជ័យ និងនាងសួស្ដីជាប្ដីប្រពន្ធ

(***សូមរង់ចាំតាមដាន រឿង ធនញ្ជ័យ ភាគទី១០ នៅសប្ដាហ៍ក្រោយ***)

អត្ថបទដោយៈ មាស សុភាព